ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...២៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ផលិតកម្ម អាហរណ-នីហរណកម្ម និងពាណិជ្ជកម្ម ឱសថបុរាណ សំរាប់វិស័យសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រក/០១៩៦/០៣ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/១៨៧ ចុះថ្ងៃទី ០៧ សីហា ១៩៩៧ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល
- បានការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៨

## ស ម្រេ ច

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

មាត្រា ១ អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងផលិតកម្ម អាហរ័ណ_និហរ័ណកម្ម និងពាណិជ្ជកម្ម ឱសថបុរាណ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ ឱសថបុរាណគឺជាសារធាតុសំរាប់ប្រើប្រាស់ក្នុងការបង្ការ ឬព្យាបាលជម្ងឺ មនុស្ស សត្វ មាន ៖

-រុក្ខជាតិ ឬសត្វ ឬសិលាជាតិដែលមិនទាន់កែច្នៃ ឬបានកែច្នៃតាមវិធីសាស្រ្តសាមញ្ញ

-ផលិតផលដែលផ្សំ ឬផលិតឡើងដោយសារធាតុមួយមុខ ឬច្រើនមុខ ដែលមានរចនាសម្ព័ន្ធគីមីមិនទាន់ច្បាស់លាស់ និងមានប្រភពពីរុក្ខជាតិ សត្វ ឬសិលាជាតិ ។

មាត្រា ៣ ផលិតកម្ម អាហរ័ណ_និហរ័ណកម្ម និងពាណិជ្ជកម្មឱសថបុរាណ អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

## ជំពូកទី ២
## សិទ្ធិធ្វើអាជីវកម្មឱសថបុរាណ

មាត្រា ៤ ឱសថការីដែលអាចមានសិទ្ធិធ្វើផលិតកម្ម អាហរ័ណ_និហរ័ណកម្ម ឱសថបុរាណ បាន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានសញ្ញាប័ត្រជាឱសថការី ទទួលស្គាល់ដោយក្រសួងសុខាភិបាល

-មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ

-មានសុខភាពគ្រប់គ្រាន់ អាចបំពេញការងារបាន ។

មាត្រា ៥ គ្រូថ្នាំបុរាណដែលអាចមានសិទ្ធិធ្វើពាណិជ្ជកម្មឱសថបុរាណ បាន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានការយល់ដឹងក្នុងការផ្សំឱសថបុរាណពីរុក្ខជាតិ សត្វ ឬសិលាជាតិ និងការពិនិត្យព្យាបាលជម្ងឺសាមញ្ញតាមវេជ្ជសាស្រ្តបុរាណ ដែលមានវិញ្ញាបនប័ត្រគ្រូថ្នាំបុរាណ ទទួលស្គាល់ដោយក្រសួងសុខាភិបាល

-មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ

-មានសុខភាពគ្រប់គ្រាន់ អាចបំពេញការងារបាន ។

មាត្រា ៦. ក្រសួងសុខាភិបាល អាចអនុញ្ញាតឱ្យឱសថការី និងគ្រូថ្នាំបុរាណបរទេសប្រកបវិជ្ជាជីវៈឱសថបុរាណក្នុងព្រះរាជាណាចក្រកម្ពុជាបាន ក្នុងករណីយល់ឃើញថា មានតម្រូវការចាំបាច់ក្នុងសង្គមជាតិ ។

មាត្រា ៧. ឱសថបុរាណដែលអាចផលិត អាហរណ៍-និហរណ៍បាន ត្រូវមានទិដ្ឋាការ ឬបញ្ជិកាយល់ព្រមពីក្រសួងសុខាភិបាល ។

មាត្រា ៨. ក្រសួងសុខាភិបាលកំណត់ដោយប្រកាសនូវ ៖

-បែបបទ និងលក្ខខណ្ឌ ក្នុងការសុំបើក ឬប្តូរទីតាំង-ឬផ្ទេរមូលនិធិនៃគ្រឹះស្ថានផលិត គ្រឹះស្ថានអាហរណ៍-និហរណ៍ និងអគារលក់ឱសថបុរាណ ។

-បែបបទ និងលក្ខខណ្ឌក្នុងការសុំទិដ្ឋាការ ឬបញ្ជិកាឱសថបុរាណ

-បែបបទ និងលក្ខខណ្ឌបច្ចេកទេសគ្រប់គ្រង និងថែរក្សាឱសថបុរាណ

-បែបបទ និងលក្ខខណ្ឌក្នុងការផ្សព្វផ្សាយឱសថបុរាណ

-បែបបទ ផលិតកម្ម អាហរណ៍-និហរណ៍កម្ម និងពាណិជ្ជកម្មឱសថបុរាណ ។

មាត្រា ៩. ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាលចំពោះ ៖

-ការបើក ការប្តូរទីតាំង និងការប្តូរអ្នកទទួលខុសត្រូវនៃគ្រឹះស្ថានផលិត គ្រឹះស្ថានអាហរណ៍-និហរណ៍ និងអគារលក់ឱសថបុរាណ

-ការផលិត អាហរណ៍-និហរណ៍ ស្តុកឱសថបុរាណ និងវត្ថុធាតុដើមសំរាប់ផលិតឱសថបុរាណ

-ការផ្សព្វផ្សាយឱសថបុរាណ ។

## ជំពូកទី ៣

## ផលិតកម្មឱសថបុរាណ

មាត្រា ១០. ផលិតកម្មឱសថបុរាណជាទ្រង់ទ្រាយឧស្សាហកម្ម ត្រូវប្រព្រឹត្តទៅនៅក្នុងគ្រឹះស្ថានផលិតឱសថ ដែលមានការរៀបចំសមស្រប តាមលក្ខខណ្ឌបច្ចេកទេសកំណត់ដោយប្រកាសក្រសួងសុខាភិបាល ។

មាត្រា ១១. ផលិតកម្មឱសថបុរាណ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការទទួលខុសត្រូវរបស់ឱសថការីមួយរូប ឬច្រើនរូបទៅតាមទំហំផលិតកម្ម

## ជំពូកទី ៤
## អាហរណ៍_និហរណកម្មឱសថបុរាណ

មាត្រា ១២. អាហរណ៍_និហរណកម្មឱសថបុរាណ ត្រូវធ្វើឡើងតាមរយៈគ្រឹះស្ថានអាហរណ៍_និហរណ៍ឱសថ ដែលមានការរៀបចំសមស្រប តាមលក្ខខណ្ឌកំណត់របស់ក្រសួងសុខាភិបាល ។

មាត្រា ១៣. ឱសថបុរាណដែលសុំនាំចូល ត្រូវជ្រើសរើសក្នុងបញ្ជីឱសថបុរាណ ដែលបានចុះបញ្ជីការួចហើយនៅក្រសួងសុខាភិបាល ។
ឱសថបុរាណដែលបាននាំចូលហើយ ត្រូវមានទម្រង់បង្ហាញ និង មានគុណភាពល្អ ត្រឹមត្រូវតាមឱសថគំរូដែលបានតំកល់ ។

## ជំពូកទី ៥
## ពាណិជ្ជកម្មឱសថបុរាណ

មាត្រា ១៤. ការតាំងលក់ ការលក់និងការស្តុកឱសថបុរាណ ត្រូវប្រព្រឹត្តទៅនៅក្នុងអគារលក់ឱសថបុរាណ ដែលមានការរៀបចំសមស្រប តាមលក្ខខណ្ឌកំណត់របស់ក្រសួងសុខាភិបាល។

មាត្រា ១៥. អគារលក់ឱសថបុរាណត្រូវមានវត្តមានរបស់គ្រូបុរាណ ដើម្បីគ្រប់គ្រងសកម្មភាពក្នុងអគាររបស់ខ្លួន ។
ករណីអវត្តមាន គ្រូថ្នាំបុរាណទទួលខុសត្រូវ ត្រូវមានគ្រូថ្នាំបុរាណមួយរូបទៀតជំនួស ដោយមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

មាត្រា ១៦ ត្រូវហាមឃាត់ ៖
១_ការលក់ឱសថបុរាណក្លែងក្លាយ គ្មានគុណភាព
២_ការលក់ឱសថបុរាណ ដែលផ្សំលាយជាមួយឱសថសម័យ
៣_ការលក់ឱសថបុរាណគ្រោះថ្នាក់ ដែលមានក្នុងបញ្ជីហាមឃាត់របស់ក្រសួងសុខាភិបាល
៤_ការប្រកបអាជីវកម្មផ្សេងទៀតក្នុងអគារលក់ឱសថបុរាណ ។

# ជំពូកទី ៦
# អវសានប្បញ្ញត្តិ

**មាត្រា ១៧.** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.** សហរដ្ឋមន្ត្រីទទួលបន្ទុកគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួង-ស្ថាប័ន ពាក់ព័ន្ធមានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ១៩៩៨

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

**អ៊ុង ហួត** **ហ៊ុន សែន**

<u>បានជំរាបជូន</u> :

-ឯកឧត្តម នាយករដ្ឋមន្ត្រីទី ១
-សម្តេច នាយករដ្ឋមន្ត្រីទី ២

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ជា.ថាង**

<u>ចម្លងជូន</u>

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យឯកឧត្តម នាយករដ្ឋមន្ត្រីទី ១
-ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី ២
-ដូចមាត្រា ១៨
-ឯកសារ-កាលប្បវត្តិ